# ឯកឧត្តម ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងពិធីផ្សព្វផ្សាយខ្លឹមសារសន្និបាតគណបក្សប្រជាជនកម្ពុជា លើកទី៣៥ អណត្តិទី៥ ជូនដល់សមាជិក សមាជិកា គណបក្សក្រសួងពាណិជ្ជកម្ម

នៅរសៀលថ្ងៃទី១៣ ខែ សីហា ឆ្នាំ២០១០ នៅភូមិគ្រឹះ ឯកឧត្តមទេសដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ស្ថិតក្នុងខណ្ឌ សែន សុខ រាជធានីភ្នំពេញ មានរៀបចំពិធី "**ផ្សព្វផ្សាយខ្លឹមសារ សន្និបាតគណបក្សប្រជាជនកម្ពុជា លើកទី៣៥ អណត្តិទី៥**" ជូនដល់សមាជិក សមាជិកា គណបក្សក្រសួងពាណិជ្ជកម្ម ដែលបានប្រារព្វធ្វើកាលពីថ្ងៃទី២១-២២ ខែកក្កដា ឆ្នាំ២០១០ កន្លងមកនេះ ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម និងជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។





បន្ទាប់ពីអង្គពិធី បានគោរពភ្លេងជាតិ និងភ្លេងបក្សរួចមក ឯកឧត្តម **គឹម ស៊ីថន** សមាជិកគណកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានគណកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម បានអានរបាយការណ៍ ស្តីពីសភាពការណ៍ និងការងារគណបក្ស ឆ្នាំ២០០៩ និងទិសដៅភារកិច្ច ឆ្នាំ២០១០-២០១១ ដែលបានបង្ហាញពីសមិទ្ធិផលធំៗ របស់គណបក្សប្រជាជនកម្ពុជាសំរេចបាន ក្នុងការរក្សានូវសុខសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយការបរទេសប្រកបដោយសុឆន្ទៈ ព្រមទាំងធានាបានយ៉ាងរឹងមាំនូវអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ដែលជាមូលដ្ឋានគ្រឹះ សំរាប់ការអភិវឌ្ឍន៍ ការលើកកំពស់ជីវភាព និងសុខដុមនីយកម្មសង្គម ។

ជាមួយគ្នានេះអង្គពិធី ក៏បានតាមដានស្តាប់សន្ទរកថា បើកសន្និបាតគណបក្សប្រជាជនកម្ពុជា លើកទី៣៥ អណត្តិទី៥ របស់**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធាន ព្រឹទ្ធសភាជាតិ ដែលអានដោយ ឯកឧត្តម **កែវ សុខណៃ** សមាជិកអចិន្ត្រៃយ៍នៃគណកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម ដើម្បីឱ្យសមាជិកសមាជិកា គណបក្សក្រសួងពាណិជ្ជកម្មយល់ជ្រួតជ្រាប ក្នុងការកំណត់ទិសដៅ ឈានទៅភាពជោគជ័យ នៃការបោះឆ្នោតនាពេលខាងមុខ ពិសេសគឺការគាំទ្រ បេក្ខភាពនាយករដ្ឋមន្ត្រីរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** សំរាប់អណត្តិបោះឆ្នោតជាតិ ក្រោយៗទៀត ។

មានប្រសាសន៍សំណេះសំណាលនាឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** សមាជិកគណកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណកម្មាធិការគណបក្សក្រសួងពាណិជ្ជកម្ម បានផ្តល់សារៈសំខាន់ ទៅលើកិច្ចប្រជុំ នាថ្ងៃនេះ គឺស្របពេលដែលគណបក្សក្រសួងពាណិជ្ជកម្ម បានរៀបចំនូវរចនាសម្ព័ន្ធចាត់តាំងថ្មី ជាពិសេស រចនាសម្ព័ន្ធ នៅតាមសាខាទាំង១៩ របស់ក្រសួងពាណិជ្ជកម្ម ដែលត្រូវបន្ថែម ឱ្យមានអនុប្រធានប្រចាំការ-អនុប្រធានទទួលបន្ទុកផ្នែកនារី-អនុប្រធានទទួលបន្ទុកផ្នែកយុវជន-និងអនុប្រធានទទួលបន្ទុកផ្នែកហិរញ្ញិក ដោយយោងទៅលើកំនើននៃសមាជិករបស់គណបក្សប្រជាជនកម្ពុជាក្រសួងពាណិជ្ជកម្ម មានរហូតដល់ **១.២១៥ នាក់** ក្នុងសមាជិកសរុប **១.២៨២ នាក់** ។ ជាមួយគ្នានេះ ក្នុងន័យដើម្បីរក្សា ពង្រីក

និងពង្រឹង ព្រមទាំងគ្រប់គ្រងសមាជិកគណបក្សប្រជាជនកម្ពុជា ឱ្យមានឧត្តមភាពកាន់តែខ្លាំងក្លា និងកាន់តែមានប្រជាប្រិយភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកយកសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងសមាជិកគណបក្ស ដែលបានចែងក្នុងសន្និបាតគណបក្សប្រជានកម្ពុជាលើកទី១៩ កាលពីឆ្នាំ ១៩៩៥ ដោយត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវសារាចរ លេខ១០ ដែលមានប្រសិទ្ធិភាពខ្ពស់ សម្រាប់ការទទួលសំលេងគាំទ្រពីប្រជាពលរដ្ឋ ទៅលើគណបក្សប្រជាជនកម្ពុជា ។